# មិនមានធានារ៉ាប់រងសុខភាពឬ? ត្រូវការសេវាកម្ម COVID-19?

Health Resources & Services Administration

## ការធ្វើតេស្ត ការព្យាបាល និង ការចាក់វ៉ាក់សាំង COVID-19 ឥតគិតថ្លៃ។

### តើអ្នកណាអាចទទួលបានសេវាកម្ម?

អ្នកណាក៏ដោយដែលមិនមានការធានារ៉ាប់រងសុខភាព ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេនោះទេ។ អាចស្នើសុំលេខសន្តិសុខសង្គម និង/ឬ អត្តសញ្ញាណប័ណ្ណរបស់រដ្ឋ ប៉ុន្តែ**មិន**ចាំបាច់នោះទេ។

### អ្វីខ្លះដែលឥតគិតថ្លៃ?

- ✓ ការធ្វើតេស្តរកជំងឺ COVID-19
- ✓ ការព្យាបាលជំងឺ COVID-19
- ✓ វ៉ាក់សាំងបង្ការជំងឺ COVID-19

### តើវាឥតគិតថ្លៃយ៉ាងដូចម្តេច?

**កម្មវិធីសម្រាប់អ្នកមិនមានធានារ៉ាប់រង\ របស់សហព័ន្ធ**បង់ថ្លៃសេវាកម្ម COVID-19 ដែលបានផ្តល់ជូនដល់ <u>បុគ្គលណាម្នាក់</u> ដែលមិនមានធានារ៉ាប់រងសុខភាព។



## ព័ត៌មានបន្ថែម

### សម្រាប់អ្នកជំងឺ

https://www.hhs.gov/coronavirus/cares-act-provider-relief-fund/for-patients

### សម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព

https://coviduninsuredclaim.linkhealth.com

### ព័ត៌មានលម្អិតសំខាន់ៗ

- **មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេវាកម្ម COVID-19 ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេនោះទេ។** ការធ្វើតេស្ត ការព្យាបាល ឬ ការចាក់វ៉ាក់សាំងដែលបានចេញប្រាក់ដោយរដ្ឋាភិបាលសហព័ន្ធ **នឹងមិនប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់បុគ្គលណាម្នាក់ ឬ ចែករំលែកជាមួយទីភ្នាក់ងារអន្តោប្រវេសន៍ឡើយ។**
- បើអ្នកមិនមានការធានារ៉ាប់រង និង ទទួលវិក្កយបត្រទាក់ទងនឹងការធ្វើតេស្ត ឬ ការព្យាបាលជំងឺ COVID-19 សូមស្នើសុំអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកឲ្យចេញវិក្កយបត្រឲ្យទៅកម្មវិធី HRSA COVID-19 សម្រាប់អ្នកមិនមានធានារ៉ាប់រងជំនួសឲ្យលោកអ្នកវិញ។
- **លោកអ្នកមិនអាចទទួលបានវិក្កយបត្របង់ថ្លៃសម្រាប់សេវាកម្ម COVID-19 បាននោះទេ ប្រសិនបើលោកអ្នកមិនមានធានារ៉ាប់រង ហើយរដ្ឋាភិបាលនឹងបង់ប្រាក់ជូនអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកសម្រាប់សេវាថែទាំរបស់លោកអ្នក។** ប្រសិនបើលោកអ្នកទទួលវិក្កយបត្រ ហើយលោកអ្នកបានបង់ប្រាក់រួចហើយ លោកអ្នកអាចត្រូវបានទូទាត់សងប្រាក់វិញ ហើយលោកអ្នកគួរតែនិយាយប្រាប់បុគ្គល ឬ ស្ថាប័នដែលបានផ្ញើវិក្កយបត្រនេះជាមុនសិន។ ប្រសិនបើពួកគេមិនលុបចោលវិក្កយបត្រនេះ ឬ សងប្រាក់លោកអ្នកវិញនោះទេ សូមទាក់ទងមកការិយាល័យអគ្គអធិការ HHS តាមរយៈលេខខ្សែទូរស័ព្ទពិសេស 1-800-HHS-TIPS ឬ ចូលទៅកាន់ https://TIPS.HHS.GOV ដើម្បីដាក់ពាក្យបណ្តឹង។
- **លោកអ្នកមិនចាំបាច់ត្រូវការលេខសន្តិសុខសង្គម ឬ អត្តសញ្ញាណប័ណ្ណរបស់រដ្ឋ** ដើម្បីទទួលបានសេវាកម្ម COVID-19 ដោយឥតគិតថ្លៃនោះទេ។
- វេជ្ជបណ្ឌិត ឱសថស្ថាន ឬ គ្លីនិកអាចស្នើសុំព័ត៌មាននេះប៉ុន្តែព័ត៌មាននេះ **បានត្រឹមតែជួយពួកគេបញ្ជាក់ថាលោកអ្នកមិនមានធានារ៉ាប់រងប៉ុណ្ណោះ**ដូច្នេះពួកគេអាចត្រូវបានបង់ប្រាក់ឲ្យដោយកម្មវិធីសម្រាប់អ្នកមិនមានការធានារ៉ាប់រង។
- **<u>លោកអ្នកនឹងនៅតែទទួលបានការព្យាបាល ការធ្វើតេស្ត ឬ ការចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 ដដែល ប្រសិនបើលោកអ្នកមិនអាចផ្តល់លេខសន្តិសុខសង្គមឬ អត្តសញ្ញាណប័ណ្ណរបស់រដ្ឋ</u>**។
- **លោកអ្នកមិនអាចទទួលបានវិក្កយបត្របង់ថ្លៃសម្រាប់សេវាចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 នោះទេ។** ប្រសិនបើលោកអ្នកទទួលវិក្កយបត្រ លោកអ្នកគួរតែនិយាយប្រាប់បុគ្គល ឬ ស្ថាប័នដែលបានផ្ញើវិក្កយបត្រនេះជាមុនសិន។ ប្រសិនបើពួកគេមិនលុបចោលវិក្កយបត្រនេះទេ សូមទាក់ទងមកការិយាល័យអគ្គអធិការ HHS តាមរយៈលេខខ្សែទូរស័ព្ទពិសេស 1-800-HHS-TIPS ឬ ចូលទៅកាន់https://TIPS.HHS.GOV ដើម្បីដាក់ពាក្យបណ្តឹង។